ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**
គណៈកម្មាធិការលទ្ធកម្ម (គល-PC)
លេខ ០១០..........សជណ/គល/១៩

## សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃផ្គត់ផ្គង់
## សម្ភារការិយាល័យ និងបរិក្ខារបច្ចេកទេសឆ្នាំ២០១៩

ទីស្តីការគណៈរដ្ឋមន្ត្រី សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា ទីស្តីការគណៈរដ្ឋមន្ត្រីនឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់សម្ភារការិយាល័យ និងបរិក្ខារបច្ចេកទេសឆ្នាំ២០១៩ ជូនគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ។

ទីស្តីការគណៈរដ្ឋមន្ត្រី បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មទីស្តីការគណៈរដ្ឋមន្ត្រី បន្ទប់លេខ ២០៩ ចាប់ពីថ្ងៃទី ២៧..... ខែ មីនា...... ឆ្នាំ ២០១៩ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០២៣ ២១២ ៤៧៩ )។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង១០ៈ១៥. ថ្ងៃទី ៣០...... ខែ មេសា....ឆ្នាំ២០១៩។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅសាលប្រជុំលេខ 1-16A វេលាម៉ោង១០ៈ១៥.....ថ្ងៃទី ៣០........ ខែ មេសា.....ឆ្នាំ២០១៩។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មីនា . ឆ្នាំ២០១៩
**ប្រធានគណៈកម្មាធិការលទ្ធកម្ម (គល-PC)**

**ធុច សុគន្ធ**

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ

**អង្គភាពលទ្ធកម្ម**
**គស.ម**